Tome-I- Roeung Sdech Khméng
A-le 29-10-52
INDOCHINE FRANÇAISE
ARCHIVES NATIONALES
COTE B-8-82
82
ទ-ទ
181



# ទី ១

## ភាគក្រោមសមុទ្រ

D-82-
B.120.1465 82

# អារម្ភកថា

លើកនេះជាល្បះចាស់ជាន់មុន ឈ្មោះហៅគឹម-ឈុនលក់សៀវភៅ

ខ្ញុំឃើញខ្សត់រឿងជាន់ឥឡូវ   ដើម្បីត្រូវចិត្តលោក-អ្នក ៗ

ខំភាវរើសរករឿងស្តេចក្មេង   ជារឿងកំផ្លែងឡើងបុណ្យសក្តិ

សុំលោកយកទុកចម្ងងដាក់   គ្រាន់បានលោក-អ្នកមើលកំសាន្ត ៗ

ទោះធ្វើដំណើរទៅតាមផ្លូវ   អង្គុយប្រចង្វ៉ូវយូរមិនបាន

ជិះទូកកុប៉ាល់ឬជិះឡាន   អបផ្សុកក្នុងប្រាណប្រឹងតែព្រួយ ៗ

បានពឹងសាយខេនឲ្យសរសេរ   តែងកាព្យទុកក្តីស្នាដៃមួយ

ដំបូងចាប់ព្រាងពុម្ពជាហើយ   លុះដល់ចុងក្រោយពុម្ពម៉ាស៊ីន ៗ

ការផ្កាយជារឿងប្រលោមលោក   ពាក្យពេជគគោកគ្មានកុកតឹង

ខ្មែរស្ទុះអត់មានលាយចាមចិន   ទោះប៉ឹនមិនប៉ឹនអធ្យាស្រ័យ ៗ

ផ្ទះលក់តាំងនៅផ្លូវវិរជង់   ថតរូបយ៉ាងខ្ញ៉ង់តែសព្វថ្ងៃ

សៀវភៅចំហៀងផ្ទៀងលេខបី   ពីររយមួយកែនឹងប្រាំបួន ៗ

រូបថតដោយបែបរឿងដោយបទ   ដាំងថតប្រាកដឡើងដោយជួន

ប្រដាប់កូនសិស្សគ្រប់សំនួន   សៀវភៅចិនយួនខ្ញុំគ្មានទេ ៗ

រឿងនេះលោកបង់បានប្រញាប់ ខ្ញុំផ្ញើទុកស្រាប់ជូនទន្ទេ

ឈ្មោះផ្លូវហៅស៊ីសុវត្ថ៍កេត្ត៍ ដែលមានសេរសេរលេខពីរ-មួយៗ

អញ្ជើញចូលទិញតាមត្រូវការ ដ្បិតផ្សារសុទ្ធចិនសូមលោកជួយ

មេត្តាជាតិខ្មែរកែក្រព្រួយ ផ្សារធំថ្ងៃក្រោយខ្មែរនៅវិញ ៗ

គួរខ្មាសយួនសៀមលាវបារាំង ផ្សារខ្មែរមិនតាំងសុទ្ធទំនិញ

បើលោកអាណិតផ្សារភ្នំពេញ សូមលោកជួយទិញខ្មែរលឿនអើយ


អ្នករៀបរៀង

សាយ.ខេង ហៅ ភឿង



ព.ស. ២៤៩៥ គ.ស. ១៩៥២

បោះពុម្ពនៅថ្ងៃ ២០ តុលា (ឧកតូប្រ៍) ឆ្នាំ ១៩៥២

ត្រូវនឹងថ្ងៃ ៣ កើត ខែកត្តិក ឆ្នាំរោងចត្វាស័ក ព.ស. ២៤៩៥

# រឿងស្តេចក្មេង

អតិតៈកាលដែលកន្លងទៅ  មានព្រះបមចៅមួយព្រះអង្គ
ព្រះនាមព្រហ្មទត្តរតនបញ្ចង់  ពូជពង្សអំបូរនៃក្សត្រា ។
សោយរាជនគរពារាណសី  ដែលមានឈ្មោះល្បីយ៉ាងអស្ចារ្យ
គបដោយសិរីជោគវាសនា  ទ្រង់រូបេស្តាយ៉ាងអង់អាច ។
សត្រូវទាំងឡាយគ្រប់ទិសទី  មិនហ៊ានយាយីតាមអំណាច
សឹងតែមានចិត្តគិតខ្លបខ្លាច  ក្សត្រាធិរាជពេកកន្លង ។
ព្រមទាំងនគរនោះតូចធំ  ដែលនៅជិតជុំក្សត្រប្លាស់ប្បង
តែងតែនាំគ្នាដើរត្រសង  យកអស់គ្រឿងផងថ្វាយចក្រ ។
មានទាំងអង្គរទឹងប្រាក់មាស  ជាច្រើនពោរពាសទាំងប្រុសស្រី
ចូលមកថ្វាយក្សត្រជាប្រក្រតី  ឥតបីមានខ្វះរាល់មាសា ។
មហាជននៅក្នុងនគរនោះ  ទាំងស្រីទាំងប្រុសគ្រប់អាត្មា
មិនដែលកើតទុក្ខមួយពេលណា  សែនមហាសុខាឥតមានមោះ ។
ដោយព្រះរាជាទ្រង់ទសពិត  កាន់ក្រិត្យវិន័យជាក់ចំពោះ
ឥតមានឲ្យល្អៀងឃ្លៀងឃ្លាតសោះ  សត្រូវទាំងអស់ញាមខ្លបខ្លាច ។

មានទាំងស្រីស្នំក្រមបរិវារ　　តែងគាល់ទ្រៀបត្រាយ៉ាងអង់អាច
ច្រៀងរាំថ្វាយក្សត្រគាល់ព្រឹកល្ងាច　　គបដោយអំណាចនៃបេស្តា ៗ
ស្តេចមានឯកអគ្គអគ្គទេវី　　នារីឈ្មោះនាងចន្ទបុប្ផា
រូបល្អទ្រៀបស្មើនឹងទេវតា　　ឥតអ្នកឯណានឹងផ្ទឹមបាន ៗ
ទ្រង់សព្វព្រះទ័យយ៉ាងពន់ពេក　　តាំងពីអភិសេកនាងកល្យាណ
ឥតមានរង្គាសដល់ក្សត្រក្សាន្ត　　តែងបានក្តីសុខនិរទុក្ខារ ៗ
ហៅសែនសប្បាយក្នុងនគរ　　មិនដែលវិកវរកើតកោលា
ដោយព្រះអង្គមានធម៌មេត្តា　　ករុណាដល់ទៅរាស្ត្រប្រជា ៗ
កាលនោះមានក្មេងទាំងប្រុសស្រី　　នៅក្នុងបុរីរាជការ
ចំនួនប្រាំរយដោយគណនា　　សឹងស្រុះចិត្តគ្នាឥតសល់ម្នាក់ ៗ
តែងបបួលគ្នាដេញគោទៅ　　ឲ្យស៊ីស្មៅព្រៃទីដែលស្ម័គ្រ
ដេញគោចុះឡើងរត់ពួនពាក់　　ក្មេងប្រាំរយនាក់សប្បាយក្រៃ ៗ
ទៅឃ្វាលទីនោះរៀងរាល់ខែ　　មិនដែលមានល្ហែឈ្លោះមួយថ្ងៃ
ដោយក្មេងទាំងនោះចេះកែខៃ　　លកលៃទើបតាំងប្រឹក្សាគ្នា ៗ
ម្តងនេះយើងលេងខុសពីដើម　　ឲ្យយ៉ាងសមល្មមនៅក្នុងថ្នា

គឺលេងធ្វើស្តេចគ្រងកាក ឲ្យឈ្មោះដាក់ងារគ្រានេះឯង ។
ដូច្នេះអ្នកណា នឹងធ្វើស្តេច សម្រេចទីនេះឲ្យដាក់ស្តង
ឆ្លើយមកភ្លាម ៗ កុំគិតក្រែង ពួកយើងនឹងលេងឲ្យហ៊ឺហា ។
ពួកក្មេងទាំងអស់ឆ្លើយឡើងកង ស្រុះគ្នាតែម្តងឥតសង្ការ
ខ្លះតាំងធ្វើនាងខ្លះបរិវ៉ា ខ្លះធ្វើសេនាគ្មានទំនេ ។
ខ្សិននោះនៅសល់ក្មេងតូចម្នាក់ មានចិត្តស្មោះស្ម័គ្រស្រស់ជាងគេ
ហេតុតែបុណ្យព្រេងពីបុព្វេ ទេវតាបង្អើមាត់អ្នកវៃ ។
ឲ្យឆ្លើយឡើងភ្លាមឥតកោតក្រែង ថាខ្ញុំហ្នឹងឯងអ្នកកុំភ័យ
នឹងធ្វើជាស្តេចទីនេះនៃ តើឯងលកលៃគិតយ៉ាងណា ។
ឯក្មេងទាំងនោះក៏យល់ព្រម ល្មាក់ល្មមដាក់ឲ្យទៅកុមារ
ឲ្យធ្វើជាស្តេចសម្រេចការ ជាទីប្រឹក្សាក្នុងការលេង ។
ស្រេចហើយនាំគ្នាសង់បន្ទាយ រួសរាយសប្បាយដោយចិត្តក្មេង
ធ្វើជារាជវាំងល្អទន្ទុង សម្រាប់ស្តេចក្មេងនៅទីនោះ ។
ក៏តាំងភ្នាក់ងារធ្វើរាជការ ពល់រូបអាត្មាតាមទាបខ្ពស់
ពីត្រឹមកុងជើកបបុះ ដល់អស់អាមាត្យទីបំផុត ។

លេងតែបែបនេះជាច្រើនថ្ងៃ សប្បាយពេកក្រៃជាក់ចំហុត
ឥតមានហេតុធ្វើឲ្យតក់ស្លុត រន្ធត់មកដល់ក្មេងទាំងនោះ ។
ស្រាប់តែថ្ងៃមួយនោះឯងណា ស្តេចក្មេងប្រាប់ថាជាក់ចំពោះ
ទើបហៅអស់គ្នាមកពីគ្រោះ ពួកយើងទាំងអស់កុំរេក ។
ចូលអ្នកចេញទៅប្រញាប់វៃ បេះផ្កាពីព្រៃមកម្នីម្នា
ឲ្យបានទាន់ពេលទាន់វេលា នឹងធ្វើបុណ្យផ្កាហែទៅវត្ត ។
ចាះស្រេចនាំគ្នាដើរត្រសង ចូលព្រៃអឹងកងក្បែរបរិពត
ក៊ិរកមើលយ៉ាងម៉ត់ចត់ ឃើញផ្កាកំរងត្នើរកស្គុះស្គាយ ។
ក៏ស្រែកហៅគ្នាមកជួបជុំ កាច់បងផាជុំខ្ទះវេចស្ពាយ
ក្មេងទាំងអស់នោះក៏រីករាយ សើចលេងគ្អាកគ្អាយយ៉ាងអឹកធឹក ។
បេះបានស្រេចហើយចរយាត្រា កាន់ផ្កានៅដៃល្អពន្លឹក
នាំគ្នាហ៊ោកងព្ធុតគ្រឹក នៅក្នុងព្រៃព្រឹក្សនោះឯងណា ។
មកដល់នាំគ្នាបងជាជុំ ធ្វើជាសំណុំនៃកួងផ្កា
ជាទីរីករាយពួកកុមារ អស្ចារ្យគួរឲ្យសើចពេកក្រៃ ។
ស្រេចហើយនាំគ្នាធ្វើត្រៃស្នង សម្រាប់ស្តេចក្មេងនោះឯងនៃ

ដើម្បីជាយានយ៉ាន់ប្រពៃ
ក្រាន់នឹងក្សត្រថ្ងៃទ្រង់ប្រថាប់ ៗ

ឆ្លើរូបនាំគ្នាទៅបង្គំ
ដល់ព្រះបរមយ៉ាន់ប្រញាប់

ដល់ហើយអាមាត្យតែងសាស័ព្ទ
រ៉ាយរ៉ាប់ក្រាបទូលដល់ក្សត្រថ្ងៃ ៗ

បពិត្រព្រះអង្គសូមទ្រង់ជ្រាប
តាមដោយសុភាពរឿងនេះនៃ

អំពីកិច្ចការដែលចក្រី
ប៉ង់ក្ទងព្រះទ័យនោះឯងណា ៗ

ខ្ញុំម្ចាស់ទាំងអស់ឆ្លើរូបស្រេច
សូមឲ្យសម្តេចទ្រង់យាត្រា

ទៅគង់លើគ្រែនឹងហែផ្កា
ដ្បិតព្រះសុរិយាជ្រេរទៅហើយ ៗ

ស្តេចក្រុងទ្រង់ជ្រាបសព្វសេចក្តី
ត្រេកអរឥតបីព្រៀបបានឡើយ

ទ្រង់ការរៀបអង្គពុំកន្តើយ
រូបស្រេចបាច់ហើយក៏យាងទៅ ៗ

មានទាំងអាមាត្យនឹងស្រីស្នំ
មកមូលជួបជុំហែចមចៅ

ចេញពីដំណាក់ត្រោះសំដៅ
ដម្រង់ត្រង់ទៅឯគ្រែស្នែង ៗ

ដល់ហើយទើបស្តេចក៏ឡើងគង់
លើគ្រែបញ្ចង់ល្អចិញ្ចែង

អាមាត្យរាជទូតក៏តាំងសែង
ស្រីស្នំនោះឯងហែតាមក្រោយ ៗ

ស្រេចហើយនាំគ្នាហោរអឹងកង
រំពងលាន់ឮជាញយ ៗ

នាំគ្នាហែដើររទៅរដ៏យ
ដល់វត្តស្រេចហើយចូលម្នា ៗ

ពេលនោះឃើញលោកនេនមួយអង្គ លោកខ្ជិតខ្ជង់ខាងវិជ្ជា

ពួកគ្រូឃើញហើយក៏ម្ម៉ា វន្ទាបង្គំទូលកិច្ចការ ។



បពិត្រព្រះគុណពេលនេះឯង ខ្ញុំម្ចាស់ខ្នះខ្នែងហៅបុណ្យផ្កា

នឹងលេងកុំសាន្តកង្ហាគ្នា ក្នុងពេលនេះណាប្រាកដស្តែង ៗ
ផ្កានោះសុទ្ធតែផ្កាឈើព្រៃ វែហមកនេះនៃគ្រាន់ជាល្បែង
ជាកិច្ចសប្បាយនៃពួកក្មេង ដើម្បីនឹងលេងឲ្យអស្ចារ្យ ៗ
ដូច្នេះខ្ញុំម្ចាស់នឹងសូមសួរ ពាក្យគួរពុំគួរសូមមេត្តា
ចុះលោកគ្រូធំនោះឯណា និមន្តយាត្រាទៅណាហើយ ៗ
លោកនេនត្រហើយក៏ឆ្លើយប្រាប់ សាស័ព្ទទៅក្មេងពុំប្រងើយ
ប្រាប់ពីគ្រូធំជាក់ជាត្រើយ ញោមអើយលោកគ្រូមន្តទៅព្រៃ ៗ
ពួកក្មេងត្រហើយបង្គិផង ដល់អង្គលោកនេនទើបចេញខ្ញី
សំដៅវិហារក្រោយចេត្តី ដល់ស្រេចហើយនៃក៏នាំគ្នា ៗ
ដង្ហែរបីជុំទើបឡើងទៅ គ្នាប្រឹទខ្លួនទៅឥតរេក
ដល់ហើយពួកក្មេងក៏វន្ទា សម្តេចគគក់ដោយស្ម័គ្រស្មោះ ៗ
ថ្វាយរូបស្តេចក្មេងឃើញដីស ហត្ថារើសយកមកបំពោះ
ដើម្បីគូសលេងក្នុងទីនោះ គូរស្រីរូបស្រស់រំពេជវៃ ៗ
ជាប់ទឹងជញ្ជាំងព្រះវិហារ យ៉ាងល្អសោភាគ្រប់ជើងដៃ
ជាក់បំណាងជើងជាប់នោះនៃ ជានាងស្រស់ស្រីក្រែបសមុទ្រ ៗ

សែនពេញហៅសំយ៉ាំងចំណាន ប្រៀបបានទៅដល់ទឹងទេវបុត្រ
អ្នកណាឃើញហើយក៏រន្ធត់ ចង់បានប្រាកដធ្វើភរិយា ។



គួររួចនាំគ្នាបរយាត្រា ចាកពីវិហារចេញម្មីម្មា
ទៅដល់កន្លែងព្រះពន្លា និត្យនៅសុខាដោយបែបបត់ ។

និយាយពីអ្នកស្រុកវិញណា ថ្ងៃនោះនាំគ្នាចូលទៅវត្ត
ទៅដល់ឃើញរូបនោះប្រាកដ កំណត់ជាប់នៅនឹងជញ្ជាំង ។
អ្នកស្រុកឃើញហើយមើលភ្លេចខ្លួន តាំងបីតាំងបួនទៅជាកាំង
ក្នុងដួងហឫទ័យស្រឡាំងកាំង នឹកស្រឡាញ់ខ្លាំងគ្រប់ៗគ្នា ។
សូម្បីអស់តាំងនាម៉ឺនផង នាំគ្នាប្រឹនកងមកវិហារ
ដោយឮអ្នកស្រុកពោលពណ៌នា ថារូបនោះណាល្អពេកក្រៃ ។
ផ្អើលតាំងចិនយួនទឹងចាមជ្វា មកមើលត្រៀបត្រាតែរាល់ថ្ងៃ
គិតថារូបនេះជាងណាទៃ បេះថ្នូល្អម្ល៉េះមិនមានទាស់ ។
មើលទៅរូបភាពស្រីនេះឯង សាច់សយ៉ាងខែងមិនមានទខ្ចូស់
ឃើញហើយស្រឡាញ់គ្រប់គ្នាអស់ គ្មានសល់ម្នាក់សោះបង់ប៉ុនប៉ង
អ្នកដែលបានឃើញរូបកញ្ញា និយាយតរតាឮអឹងកង
ដរាបទឹងដល់ក្សត្រប្រាសប្បន ទើបស្ដេចត្រាស់ផ្គងទៅសេនា ។
ពេលនេះចូលឯងរៀបប្រដាប់ ទឹងហៃអញឆាប់ប្រញាប់ការ
ទៅកាន់អារ៉ាមកុំសារ៉ា ដ្បិតឮគេថាជាក់ប្រាកដ ។
មានអ្នកឯណាគូររូបស្រី យ៉ាងស្រស់ប្រិមប្រិយល្អហ្មត់ចត់

ដាក់ចំណងជើងនារីរត្ន ឈ្មោះក្របសមុទ្រគួរស្នេហា ។
សេនាព្រះហើយរៀបខ្លួនប្រាណ ស្មោះស្មានក្នុងចិត្តឥតសង្ការ
មិនបានបង្អង់ទូលក្សត្រា ពិតព្រះឱង្ការរួចស្រេចហើយ ។
ព្រហ្មទត្តបានព្រឹករៀបអង្គ យាងស្រស់បញ្ចង់ពុំលង់ឡើយ
ទុបតែងព្រះអង្គក្សត្រត្រានត្រើយ ឱង្ការថាអើយពួកសេនីយ ។
មានអស់បរិវារចោមរោមកង នៃក្សត្របក្សច្បងនរព្វតី
ព្រមទាំងនាម៉ឺនមុខមន្ត្រី ហែព្រះបក្រីអង្គក្សត្រា ។
សំដៅឆ្ពោះទៅឯវត្តលោក គ្នាប្រឹងគរគោកយ៉ាងអស្ចារ្យ
ទៅដល់ទីវត្តស្រេចហើយណា ក្សត្រាទតយល់រូបនោះឯង ។
មើលទៅយ៉ាងល្អស្រស់ចំឡែក ប្លែកអស់គំនូរគេដាក់ស្តែង
ជាងណាក៏គេចេះតាក់តែង ឲ្យអញចំបែងក្នុងកាយា ។
ទើបស្តេចចូលទៅថ្វាយបង្គំ ដល់លោកគ្រូធំតាំងស្វួរការ
បពិត្រព្រះគុណពេលនេះណា សូមមេត្តាប្រាប់សេចក្តី ។
ពីណាគូររូបក្នុងវិហារ នាម្ចាស់នោះតើឈ្មោះអ្វី
ដាក់ចំណងជើងគួរប៉ែតតី ថានាងស្រស់ស្រីក្របសមុទ្រ ។

ដូច្នេះព្រះគុណសូមសារសព្វ ប្រាយប្រាប់មកខ្ញុំដោយចំហុត
ឲ្យខ្ញុំបានដឹងជាក់ប្រាកដ ពីក្រែបសមុទ្រនេះឯងណា ៗ




លោកគ្រូឮហើយទើបឆ្លើយទៅ ក្រាបទូលបមពៅអគ្គក្សត្រា

ថ្វាយទៅសម្តេចព្រះករុណា    អាត្មាឥតបានដឹងការដាក់ ។
លោកនេនទៅជិតគ្រូធំនោះ    ទូលទៅចំពោះព្រះទ្រង់លក្សណ៍
អាត្មាបានឃើញក្មេងច្រើននាក់    ហែផ្កាប្រទក្សវត្តនេះណា ។
ទើបនាំគ្នាចូលព្រះវិហារ    ដាក់ផ្កាបូជានមស្ការ
ថ្វាយរួចពួកក្មេងចរយាត្រា    គួររូបធិតានេះឯងនៃ ។
ព្រះអង្គឮហើយទើបត្រាស់ថា    ទៅកាន់សេនាំពេចវៃ
ហេតុនេះចូលឯងទៅឃ្មាតខ្ទី    រកក្មេងនោះនៃមកឲ្យឆាប់ ។
ទឹងសួរដំណើរ ដើមទងវ៉ា    ចូរឯងយាត្រាទៅប្រញាប់
សេនាឮហើយរត់តានតាប់    ដើម្បីទឹងចាប់កុមាក ។
ទៅដល់ឃើញស្តេចក្មេងចំពោះ    និត្យនៅទីនោះយ៉ាងសង្ហារ
មានអស់អាមាត្យផាបវ៉ា    ច្រើនមីត្រៀបត្រាក្នុងបន្ទាយ ។
អាមាត្យចូលទៅស្រេចហៅថា    អើនៃអាវ៉ែមកឯអាយ
ព្រោះដង្វិតក្សត្រាគង់នៅនាយ    ឲ្យឯងទាំងឡាយទៅគ្រានេះ ។
ស្តេចក្មេងឮហើយនាំសេនា    ដើរចេញយាត្រាដោយចិត្តរិះ
គិតដល់ចមពង់តែងសន្ទីស    ត្រាស់ហៅពេលនេះមានការអ្វី ។

នាំពលដើរទៅចូលក្នុងវត្ត ឃើញស្តេចព្រហ្មទត្តនឹងសេណី
ស្តេចក្មេងទូនកប្រាបសិរីសើ ចាំស្តាប់សេចក្តីព្រះឧង្គារ ៗ
ស្តេចត្រាស់ថាហើយអាអស់គ្នា គួរក្នុងវិហាររូបកញ្ញា
ជាប់ទឹងផ្ទាំងតើឈ្មោះណា ប្រាប់ឲ្យឆាប់កុំលាក់ឡើយ ៗ
គួររូបនារីស្រីក្រែបសមុទ្រ រូបស្រស់ប្រាកដពេកណាស់ហើយ
ឈ្មោះណាប៉ុនគួរកុំប្រងើយ ប្រាប់កុំកន្តើយឲ្យដឹងពិត ៗ
ស្តេចក្មេងឮហើយឆ្លើយថាខ្ញុំ គួរតាមនិយមដោយចិត្តគិត
បេះតែគួរទៅរូបវរមិត្ត មិនដឹងឆោមស្ងួនទៅស្ថានណា ៗ
ព្រហ្មទត្តបានដឹងសព្វសេចក្តី ទើបត្រាស់ទៅវរកុមារ
ដែលប៉ុនប្រសព្វគួរកញ្ញា ទៅរកធីតាស្រស់ទួនល្អ ៗ
អញបានឮគេនិយាយស្តី ថាស្រីរូបល្អស្រស់ឥតហ្មង
នៅឋាននាគានោះជាម្តង ទៅយកមកហោងឲ្យខ្លួនអញ ៗ
បើមិនទៅទេទាំងអស់គ្នា មុខជាវេទនាអញចង់បាញ់
ទាំងតូចទាំងធំឲ្យអស់ចេញ ទុកនាំកើតខ្ញាញ់ក្នុងសន្តាន ៗ
ស្តេចក្មេងឮហើយឆ្លើយទៅខ្ញុំ ទូលព្រះបរមក្សត្រក្បាន

យើងខ្ញុំតាំងអស់រកកល្យាណ៍ បើបានមិនបានសូមមេត្តា ។
ពេលនេះសុខចិត្តតែចេញទៅ រកស្រស់ពាលពៅថ្វាយក្សត្រា
សូមឲ្យព្រះអគ្គរៀបកេត្រា ព្រមស្បៀងអាហារទៅដោយផ្លូវ ។
ហេតុនេះសូមទ្រង់ចាត់ទៅចុះ ខ្ញុំទៅតាំងអស់ពេលនេះគួរ
នឹងរកឆោមឆាយថ្វាយបមពៅ ឲ្យបានត្រឹមត្រូវដូចពណ៌នា ។
ព្រហ្មទត្តបានឮស្ដេចក្មេងថា នាំពលសេនាចូលគាល
ចាត់ពួកមន្ត្រីតាំងអស់គ្នា ឲ្យរៀបនាវាក្នុងជលសា ។
ថ្លែងពីព្រះចៅរៀបស្រេចហើយ យើងស្ដីកន្ដើយពីកុមារ
ទៅផ្ទះរៀបខ្លួនគ្រប់អាត្មា ប្រាយប្រាប់មាតានឹងបី ។
ផ្សិតខ្ញុំគួរលេងរូបកញ្ញា ស្រាប់តែក្សត្រាឲ្យរកស្រី
នៅឋាននាគាឆ្ងាយឥតបី ព្រឹកនឹងលាខ្ញុំទៅប្រាកដ ។
ម្ដាយ ៗ ពួកក្មេងព្រួយកន្លង ស្រែកដេអឹងកងដោយកំណត់
ក្អើ ៗ ទៅគួររូបក្នុងវត្ត អាងប្រាកដដាច់សេរិសី ។
ក្អើ ៗ ទៅលេងមិនគួរការ នាំឲ្យក្សត្រាមិនប្រណី
អញសក់កក្រុលស្គូវមិនដឹងអី ឋាននាគនោះនៃនៅត្រង់ណា ។

កូនព្រួម្តាយដេក៏ឆ្លើយប្រាប់ ធ្វើម្តេចបើស្លាប់តាមវាសនា
បើគេមិនបានថ្វាយក្សត្រា សូមថ្វាយជីវាលុះក្សិណក្ស័យ ៗ
ម្តាយ ៗ ថាបើអាគិតច្នោះ ទៅចុះអញក៏ដាច់អាល័យ
កុមារទាំងអស់នាំគ្នាវៃ ហាក់ដូចគ្មានកែទៅនាក ៗ
ពួកគេក្នុងចុះបាត់ស្មាត់អស់ហើយ ថ្ងៃពីគ្រានទ្រើយព្រះពជា
ហៅពលមកខ្ទីទៅពណ៌នា ឯងទាំងអស់គ្នាចាំស្តាប់ការ ៗ
ឯងទៅជាមួយនឹងនាក រកស្រីពុំធ្លារបានកាលណា
ចោលឲ្យស្តេចក្នុងវង់ទុក្ខា នៅក្នុងផលសានោះទៅចុះ ៗ
យកតែប្អូនស្រីមានរូបល្អ សាច់សោតក៏សរក្រៃយ៉ាងស្រស់
ឲ្យតែយកបានរូបនាងស្មោះ អាឯងទាំងអស់អញឱ្យស័ក្តិ ៗ
អាមាត្យព្រះហើយបង្គំខ្ទី ចរចុះទៅវៃដោយស្មោះស្ម័គ្រ
មនុស្សក្នុងសំពៅប្រាំរយនាក់ បើកចរចេញដាក់តាមផល្វូសា ៗ
ស្តេចក្នុងថាយើងពេលនេះឯង នឹងខំស្វះស្វែងរកធីតា
មិនដឹងជានាងនៅត្រង់ណា កើតព្រួយសង្ការពោកកន្ទុង ៗ
ដូច្នេះយើងផ្សងទៅតាមបុណ្យ គ្រែងគុណលោកជួយពេលនេះម្តង

ថាស្រេចស្ដេចក្មេងលើកដៃផ្គង    ទាំងសងបង្គំដល់ទេព ។
បពិត្រព្រះឥន្ទ្រទីព្រះព្រហ្ម    ដែលលោកជាធំនៅសួគ៌ា
ពេលនេះសូមលោកជួយមេត្តា    ដល់ខ្ញុំករុណាជាក់បំពោះ ។
សំពៅបេះតែបើកសំដៅ    ក្នុងទឹកខ្វលខ្មៅគួរស្រណោះ
ឃើញសត្វហ្វូងត្រីនៅទីនោះ    ស្ដេចក្មេងពីគ្រោះដោយកើតទុក្ខ ។
ហើយឯងរាល់គ្នាចូលមកណោះ    មើលហ្វូងត្រីកេសកែអផ្សុក
ដូចយើងឃ្លាតចាកអំពីស្រុក    ត្រីក្អកបែកមុខឪពុកម្ដាយ ។
ត្រីក្រាញ់ហាវសែនក្រៀមក្រំចិត្ត    ត្រីក្អិតព្រោះឃ្លាតចោលស្រុកឆ្ងាយ
ត្រីឆ្តោទឹកឡើងគួរឲ្យស្ដាយ    ព្រោះលេងសប្បាយឲ្យលំបាក ។
ឃើញកេកគង់ចិត្តសែនគិតគៃ    លុះដល់ឃើញត្រីដូទ្រង់ខ្សាក
ត្រីរាស់ស្លាប់រស់ព្រោះគោកយ៉ាក    កន្ទ្រាប់កន្ទ្រាក់ចិត្តគិតទៀត ។
ឃើញត្រីចង្វាហែលចង្វាត់    វិញ្ញាណរសាត់ទ្រង់សឹកសៀត
ត្រីព្រលទឹកព្រួយក្រែងចោលធាតុ    ខំឃ្លាតមើលត្រីកំសាន្តចិត្ត ។
ច្រើនយប់ច្រើនថ្ងៃក្នុងសំពៅ    ទឹកទៅវែងខ្វល់វល់គំនិត
ពេលថ្ងៃក៏គិតយប់ក៏គិត    ផ្សងតាមនិម្មិតព្រេងវាស្នា ។

បើកទៅក៏ណាត់បីខែគត់ នៅក្នុងសមុទ្រទីជល្សា
មើលទៅអស់ស្បៀងទឹងអាហារ នៅក្នុងកេ្រាជិតរស់ហើយ ៗ



ស្រាប់តែស្តេចក្មេងមើលឃើញកោះ ទិត្យនៅទីនោះទើបអ្នកត្រើយ

ព្រាយព្រាប់សេនាមិនកន្តើយ ថាដល់កោះហើយយើងពល់គ្នា ។
ទើបបើកសំពៅចរចូលទៅ សំដៅកោះនោះមិនមានទក
ដល់ហើយទើបនាំគ្នាម្នីម្នា ចុះពីកេត្រាដើដល់ដី ។
ស្ដេចក្មេងក៏តាំងបង្គាប់ថា ហៃអស់សេនាទាំងសេនីយ
ព្រមទាំងនាម៉ឺនទាំងកុង្សី ចូរឯងឃ្មាតខ្មីពេលនេះណា ។
ទាំងកាប់ឈើព្រៃយកដីដាំ ទាំងដាក់ដំណាំជាអាហារ
ព្រោះស្បៀងដែលនៅក្នុងកេត្រា ជិតអស់ហើយណាពេលនេះនៃ ។
សេនា[illegible]ហើយក៏កាប់ឆ្កា អស់ទាំងរុក្ខាផងទីទៃ
មិនមានឲ្យសល់នៅក្នុងព្រៃ រួចស្រេចបាច់ខ្ទីទើបនាំគ្នា ។
ដាំអស់ដំឡូងទាំងពោតផង ច្រើនក្រៃកន្ទុងឥតគណនា
ព្រមទាំងឪឡឹកទាំងបេកជ្វា តាសក់សៃជាមិនសល់អ្វី ។
ដាំរួចនិត្យនៅទីនោះឯង អ្នកតែងដើរមើលជាប្រក្រតី
ឃើញអស់ដំណាំដុះខៀវខ្ចី ដោយដីនោះល្អប្រាកដជាក់ ។
លុះដល់កំណត់បីខែពិត ដំណាំរឹងរិតដុះស្មោះស្ម័គ្រ
មានផ្លែមានផ្កាច្រើនឥតអាក់ អាណែកអាណាក់ច្រើនកន្ទុង ។

ស្រាប់តែថ្ងៃមួយនោះឯណា　មានអស់ហ្វូងស្វាដើរត្រសង
ចូលមកចំការក្មេងនោះហាន　ឃើញផ្លែឈើផងក៏បេះទៅ ។
ថ្វាយស្តេចស្វាសារនោះឯណា　ព្រមទាំងកិរិយាដែលនិត្យនៅ
ក្នុងដងអាត្មានៃព្រៃជ្រៅ　ពួកស្វាសំដៅមិនរេក ។
យកពោតទៅថ្វាយព្រះបក្រី　ជាម្ចាស់សេរិសីទាំងអស់គ្នា
ស្តេចស្វាទទួលដោយម្ចីម្ចា　បានពោតបេកថ្វាមកពីណា ។
សេនីយព្ទហើយក៏ឆ្លើយប្រាប់　សារស័ព្ទដល់អង្គម្ចាស់សិរីសា
ថាខ្ញុំបេះមកពីចំការ　សូមព្រះករុណាជ្រាបសេចក្តី ។
ស្តេចស្វាថាស្អែកអញទៅដែរ　ចូលឯងចាំហែណាសេនីយ
អញចង់ទៅស្គាល់ឲ្យដឹងក្តី　ព្រោះពោតខ្ចីៗល្អណាស់សា ។
ពួកក្មេងថ្ងៃនោះដើរមើលពោត　ឃើញស្វារំហូតឥតសង្ការ
ទូលស្តេចទ្រង់ត្រាស់ឲ្យធ្វើក្តា　ទិងចាប់សត្វស្វាចៅព្រៃនេះ ។
ពួកយើងជីកដីកំសង់ស្រយ　ដាក់ក្តាក្រោបវិកំសន្ទីស
ពួកស្វាមុកមកក្នុងទីនេះ　ឃើញស្អាតឡើងជិះប្រាកដហើយ ។
ស្តេចក្មេងថាឯងជីកចាប់ទៅ　ក្នុងពេលឥឡូវកុំកន្តើយ

សេនាបានឮមិនប្រើយ ថាឱម្ចាស់អើយកុំព្រួយអ្វី ។
ខ្ញុំម្ចាស់នឹងដឹកពេលនេះឯង ខ្នះខ្នែងថ្វាយដល់ព្រះចក្រី
ថាហើយនាំគ្នាដឹកឃ្លាតខ្លី រួចស្រេចហើយនៃទើបដាក់ក្តា ។
ស្តេចក្មេងក៏ចូលក្នុងទីនោះ បំពោះក្នុងចិត្តឥតសង្ការ
ដោយនឹកក្តៅចិត្តនឹងហ្វូងស្វា វាបេះផ្លែផ្កាមិនមានសល់ ។
ស្អែកឡើងពួកស្វាដើរត្រសង ហែស្តេចវាផងទើបមកដល់
មើលទៅឃើញក្តាដាមណ្ឌល ប្រាប់អស់ពួកពលបេះប្រញាយ ។
ខ្លួនឯងទៅអង្គុយលើក្តា យ៉ាងស្រស់សង្ហារឥតខ្វល់ខ្វាយ
កន្ទុយដាក់ចុះវែងអន្លាយ ប៉ះកាយស្តេចក្មេងចាប់បានហោង ។
ស្រែកឮហ្វាច ៗ ត្រហឹងព្រៃ សេនាគិតភ័យរត់ត្រសង
នៅតែស្វាសរនោះជាម្តង ភ័យខ្លាំងកន្លងឥតឧបមា ។
ទើបនិយាយឡើងអង្វរករ ដល់ព្រះកូឋម្ចាស់សេរីសា
ឱព្រះគុណអើយសូមមេត្តា ករុណាដល់ខ្ញុំពេលនេះឯង ។
ស្តេចក្មេងក៏តាំងឆ្លើយឡើងថា ពេលនេះឯងណាកុំគិតក្រែង
អញខឹងខ្លាំងណាស់អញមិនលែង អញនឹកចំបែងពេកណាស់សា ។

ដំណាំអញឯងអាបេះអស់
មិនមានចន្លោះសល់ត្រង់ណា
ពេលនេះអាឯងកុំសង្ការ
នឹងសូន្យជីវ៉ាពេលនេះហើយ ៗ
ស្តេចស្វាឮហើយភ័យរន្ធត់
ស្រយុតអស់ប្រាណពុំមានស្បើយ
អង្វរថាឱព្រះគុណអើយ
សូមព្រះត្រានិត្រើយលែងខ្ញុំទៅៗ



ខ្ញុំនឹងឲ្យកែវមួយដល់ម្ចាស់
ក្នុងពេលនេះបង្ហាស់មិនទុកនៅ
ថ្វាយដល់ព្រះអង្គពេលឥឡូវ
ឲ្យតែបមហៅទ្រង់មេត្តា ៗ

កែវនេះពូកែមានរិទ្ធិណាស់ ហើយមានដេជះយ៉ាងអស្ចារ្យ
អាចនឹងមុជដែកក្នុងជល្សា ប្រាថ្នាតាមចិត្តបានទាំងអស់ ។
កែវនេះអាចរត់លើទឹកបាន សូមព្រះក្សត្រក្រាបយកទៅចុះ
ថាស្រេចស្ដេចស្វាហុចចំពោះ ដល់ព្រះទ្រង់យស់ឥតសង្ស័យ ។
ស្ដេចក្មេងត្រេកអរយ៉ាងពន់ពេក ក្រឡេកឃើញកែវពេញចិត្តក្រៃ
ទទួលយកបានស្រេចហើយនៃ ព្រះទ័យគិតថៃលទឹងសួរការ ។
ទើបឡើងមកតាំងនិយាយលេង ឥតមានកោតក្រែងនឹងស្ដេចស្វា
ពានរក៏សួរទៅក្សត្រា ម្ចាស់យានទៅណាប្រាប់ទំនង ។
ស្ដេចក្មេងក៏ឆ្លើយទៅវិញស្មោះ យើងប្រាប់ឲ្យអស់ឥតមានហ្មង
ថាអញទៅនេះព្រួយកន្ទុង ដ្បិតក្សត្របក្សាស់ប្បងទ្រង់ត្រាស់ថា ។
ឲ្យទៅយកស្រីក្រេបសមុទ្រ ប្រាកដមិនដឹងនៅទីណា
ហេតុនេះអញព្រួយក្នុងចិន្ដា នាំអស់សេនាចំស្វះស្វែង ។
ស្វាឮព្រះអង្គប្រាប់សេចក្ដី ទើបទូលវិញខ្ញុំដោយជាក់ស្ដែង
ពេលនេះព្រះអង្គកុំគិតក្រែង ខ្ញុំឯងនឹងទូលតាមទំនង ។
បើស្ដេចយានទៅកាប់កន្ទុង សំបូរសព្រឹងសប្ហាផ្សេង

បណ្តែតទៅចុះតាមដោយផង　ស្តេចគង់នឹងបានឃើញប្រាកដ ៗ
បើកន្ទូងនោះលិចត្រង់ណា　សូមឲ្យក្សត្រាគិតបែបបទ
បោះយុតថ្កាចុះដោយសន្តិ　ហើយយកកែវរតន៍ជ្រកគ្គារ ៗ
ស្តេចក្អែកឮស្វាទូលដូច្នោះ　ត្រេកអរក្នុងពោះមហិមា
ស្វាសរឡើកូនទៅភ្លា　ហើយកប់អានគ្នាពេលនោះហោង ៗ
ស្រេចហើយសុំធ្វើជាមិត្រភក្ត្រ　កុំឲ្យអន់អាក់កាលស៊ីសង
ស្តេចក្អែកយល់ព្រមឥតមានហ្អង　ស្វាអរកន្ទុងនឹងក្សត្រថ្ងៃ ៗ
ព្រះអគ្គីមានព្រះឧង្ការ　អស់ឯងពលគ្នាចូលលកលៃ
នឹងបេះដំណាំនៅក្នុងព្រៃ　ដាក់កេត្រាវៃកុំវេរា ៗ
សេនាព្រះហើយបេះដំណាំ　ដែលខ្លួនបានដាំទាំងអស់គ្នា
ដើម្បីទុកធ្វើជាអាហារ　ដាក់ក្នុងកេត្រាស្រេចហើយហោង ៗ
រួចហើយស្តេចក្អែកលាស្តេចស្វា　នឹងអាលយាត្រាចេញទៅផ្គង
យកទាំងកូនស្វានោះទៅផង　ដាក់កេត្រាហោងពុំរង់នៅ ៗ
ទឿនអស់ពួកពលរៀបនាវា　នឹងអាលលេលាបើកសំពៅ
កណ្តាលសមុទ្រទឹកជ្រាលជ្រៅ　ហូរគួចខ្វល់ខ្វាំអស្ចារ្យក្រៃ ៗ

មើលឃើញតែទឹកនឹករលក　មេឃនឹងពពកគួរឲ្យភ័យ
កណ្ដាលសមុទ្រនោះឯងនៃ　ទើបស្ដេចលើកដៃតាំងសច្ចា ៗ
បន់ទៅព្រះឥន្ទ្រនឹងទេព្រ័ក្ស　អារុក្ខអារក្ខនៅទេវតា
ដែលលោកឋិតនៅលើផល្សា　សូមលោកមេត្តាជួយកៃខៃ ៗ
បន់ស្រេចស្ដេចឲ្យកាប់កន្ទួង　មានសាស្រ្តកយានជិតនឹងដៃ
ហើយតាំងបន្ទូតលឿនពេកក្រៃ　ប៉ះខ្សែទឹកវៃគួបលិចបាត់ ៗ
ស្ដេចក្មេងប្រាប់ក្ដាមទៅសេនា　ថាឯងរាល់គ្នាមកណោះថ្ងាត់
ទឹងបោះយុគថ្កាប្រុងប្រយ័ត្ន　កុំឲ្យរំសាត់ពេលនេះឯង ៗ
ត្រូវនាំគ្នាឃាមកុំប្រហែស　មើលណុះមើលណោះគ្រប់កន្លែង
យប់ថ្ងៃក្ដីណាគោងគិតក្រែង　យើងទុកចិត្តឯងទាំងអស់គ្នា ៗ
ចាំឃាមប្រវ៉ាក់ឲ្យមាំមួន　កុំគេបដេកពួនឲ្យខូចការ
ទោះបីយូរឆាប់ច្រើនមាសា　នោះត្រូវតែចាំកុំបីភ្លេច ៗ
បើអញទៅដល់បរិបូណ៌បាន　យកស្រីកល្យាណមករំពេប
កន្ទ្រាក់សាស្រ្តកដែលលង់លិច　ត្រូវគេបស្រាវក្ដាមកុំឲ្យយូរ ៗ
ក្រែងណោស្ដេចនាគដេញតាមទាន់　នាំឲ្យកើតការខូចការស៊ូ

ព្រោះនៅក្នុងទឹកដូចក្នុងទូ    សត្វត្រីជាប់ទ្រុងរំស្លាប់បាន ។
ត្រាស់ក្លាមស្តេចក្មេងតែងគ្រឿងគ្រប់ ដែលព្រះបមកប់ទ្រង់ប្រទាន
មកុដទំរង់ទ្រង់ស្វរិតាន    ប្រដាប់ប៉ុន្មានគ្មានខ្វះអ្វី ។
ព្រះហស្តកាន់កែវបានពីស្វា    ហើយទ្រង់សង្វាមានរស្មី
យកកូនពានរពារនៅដៃ    ផ្តាំស្រេចក្សត្រថ្ងៃរៀបចាត់ចែង ។.
ដូច្នេះនាំគ្នាដាក់សៅផែក    អញ្ជនឹងមុជផែកមិនកោតក្រែង
ទៅក្នុងសមុទ្រឲ្យដាក់ស្តែង    នឹងស្វែងទៅរកឋាននាគា ។
និយាយអំពីគួរសៅផែក    ធ្វើនោះនឹងផែកឥតរេក
រួចស្រេចចាប់ចុះក្នុងផល្លូសា    ដាក់ស្តេចនឹងកូនស្វានោះនៃ ។
ចុះទៅដល់ឋានពូជង់នាគ    ស្តេចក្មេងបែងាកឃើញបុរី
ដល់ហើយកុមារចូលទៅវ័យ    ដើរក្បែររាំងដៃមិនភ័យកិត ។
ទៅដល់ឃើញផ្ទះយាយមាណា    ដែលនៅក្បែរផ្កានោះឯងពិត
ដៃបីកូនស្វាហើយរិះគិត    អ្នកក៏ពិនិត្យឡើងទៅខ្ញុំ ។
ឯយាយមាណាក៏សួរថា    អ្នកមកពីណា សូមហាស្តី
ប្រាប់មកឲ្យខ្ញុំដឹងសេចក្តី    កុំឲ្យសង្ស័យក្នុងចិន្តា ។

ស្តេចក្រោធក្រៃហើយក៏ឆ្លើយប្រាប់ សាវសត្វទៅយាយមាលាផ្កា

សុំផ្ទះសំណាក់តាមពៅហា ថាខ្ញុំនេះណាធ្វើជំនួញ ។

ព្រោះពុំថានៅឋាននាគា បង់បានប្រែជាទើបខំជួញ

មកពីមនុស្សលោកមិនរួញ គង់គួញបង់មកលេងផងណា ។

យាយតាគត់ក៏មើលទៅប្រក្រិ ឃើញគ្មានទាស់អ្វីក្នុងចិន្តា

នេះប្រាស់ជាពូជពង្សក្សត្រា បានជាអស្ចារ្យពន់ពេកណាស់ ។

គួរឲ្យអញ្ញឯងទឹកពីផល ព្រោះមិនដែលយល់ពេលនេះប្រាស់

ឥឡូវមកសុំសំណាក់ផ្ទះ ជូនចាស់ក៏ព្រមលែងសង្ស័យ ។

ស្តេចក្រោធសួរយាយមាលាថា យាយឯងកាត់ផ្កានេះធ្វើអ្វី

ប្រាប់មកឲ្យខ្ញុំដឹងសេចក្ដី ក្នុងពេលនេះនៃជាក់ចំហុត ។

យាយក៏ប្រាយប្រាប់តាមទំនង ខ្ញុំកាត់ផ្កាក្រងតាមកំណត់

យកទៅថ្វាយនាងក្រេបសមុទ្រ ពុំដែលឲ្យផុតមួយវេលា ។

ឮហើយថាអញពេលនេះឯង ដែលខំសួរស្វែងរកពុំបាន

ឥឡូវបានជួបនឹងស្ងួនភ្ងារ ក្នុងពេលនេះណាប្រាកដជាក់ ។

គិតស្រេចស្តេចសុំជួយកាត់ផ្កា យាយមាលាណាដោយស្មោះស្ម័គ្រ

យាយប្រាក៏ព្រមមិនអន់អាក់ ទ្រង់លក្ខណ៍កាច់ផារូបភផហង្ស ។
ទឹនអស់កិន្នរផងទាំងឡាយ ដើររាំកែក្រាយល្អបញ្ចង់
កាច់រូបកេសសរនឹងវរវង្ស ដែលដើរនៅក្នុងព្រៃព្រឹក្សា ។





កាច់រូបដល់ពេលដែលយកទៅ ថ្វាយបុត្របមចៅវត្ថធិតា
នាងនាទឃើញហើយក៏សួរថា ផ្កានេះអស្ចារ្យបំឡែកក្រៃ ។
យាយក្រង់ខ្ញុំនឯងប្អូនរណា សូមយាយបរចាប្រាប់មកវៃ
ព្រោះផ្សេងគបិត្តខ្ញុំទឹកសង្ស័យ រូបក្រង់ខុសដែពីធម្មតា ។
យាយក៏ក្រាបទូលទៅវិញខ្ញុំ បពិត្រក្សត្រីម្ចាស់សិរីសា
ឯជាងដែលឆ្នៃគឺមនុស្សា មកពីសេមាពាកណសី ។

រូបកាយ៉ាងល្អស្រស់បំព្រែក ត្រូវភ្នែកដូនណាស់ឥតទាស់អ្វី
សម្បុរលឿងទុំស្រស់ទេវខ្ចី គួរឲ្យប៉ើតយៃពេកកន្លង ៗ
មានទាំងកូនស្វាមកជាមួយ គាត់តែងលើកស្ទួយបីត្រកង
បើសិនជាបានម្ចាស់ឯងហោង សុំគ្នាកន្ទង់ណាកែវស្រី ៗ
នាងក្រាបសមុទ្រញាំពោះ ទើបនាងពីគ្រោះនឹងយាយខ្ចី
បើពិតដូចយាយឯងហាស្តី ស្អែកយាយកុំភ័យយកស្វាមក ៗ
ដើម្បីឲ្យខ្ញុំបានឃើញផង សត្វស្វានោះហោងព្រោះនឹកក្នុង
ស្អែកយាយកុំខានសូមលៃលក កុំឲ្យខ្ញុំខកពេលនេះណា ៗ
ស្រេចហើយក៏យាយបង្គំលា បរចេញម្ពីម៉ាទៅគេហា
ដល់ហើយក៏យាយប្រាយប្រាប់ថា ដល់អង្គកុមារស្តេចក្មេងនោះ ៗ
ថានាងចង់បានកូនស្វាទៅ ក្នុងពេលឥឡូវជាក់ចំពោះ
ហេតុនេះសូមឲ្យអ្នកអនុគ្រោះ សង្គ្រោះស្ងោះពេលនេះកុំគិតក្រែង ៗ
ស្តេចក្មេងក៏ឲ្យតាមបង្គាប់ ព្រោះចិត្តចង់ផ្តាច់រឿងដែលស្វង
យាយយកទៅចុះពេលនេះឯង តុបតែងឲ្យសត្វធ្វើចៅមហា ៗ
យាយឮដូច្នោះត្រេកអរក្តាត់ បីស្វាចុះផ្ទាត់ចូលសេមា

ដល់ហើយចូលថ្វាយនាងធិតា រួចស្រេចហើយណាវិលវិញខ្មី ។
ស្វានោះតែងតែនិយាយឡុក ចំអកចំអន់នាងក្សត្រី
ថាម្ចាស់ទឹងម្ចាស់ខ្ញុំនេះនៃ សំគ្នាឥតអ្វីប្រៀបស្មើបាន ។
មើលទៅចង្កើះនឹងមុខមាត់ ដូចគ្នាប្រាកដដោយស្មោះស្មាន
បើសិនជាម្ចាស់ខ្ញុំនឹងបាន រួមថានជាគូឥតមានហ្មង ។
នាងក្របសមុទ្រឮវាចា អំពីកូនស្វាបេះឪដង
នាងនឹកឡើងខ្មាស់ពេកកន្លង ទើបនាងត្រាស់ផ្គងទៅវិញថា ។
នាងកុំនិយាយពាក្យដូច្នោះ ពាក្យនេះវាខុសនឹងជំរ៉
ប្រាប់ពីបុរាណនោះឯងណា ថ្ងៃក្រោយកុំថាដូច្នេះឡើយ ។
ប៉ុន្តែចិត្តនាងនឹកកន្ទេង ដល់ទៅស្ដេចក្មេងពុំមានស្បើយ
ធ្វើម្ដេចនឹងបានជួបគ្នាឡើយ ព្រះសើយមុកឲ្យខ្ញុំសង្ការ ។
គ្រាន់តែឮឈ្មោះមិនបានយល់ តួអង្គទស់ពល់នឹងនេត្រា
ឮតែសំដីដោយសារស្វា ឲ្យខ្ញុំទុក្ខាពេកកន្ទង ។
លុះដល់ពេលព្រឹកយាយមាលា កាប់ផ្កាម្លីម្លានឹងប្រាសប្ចង់
យកទៅថ្វាយទៀតដូចសព្វដង ស្វានឹងនួនល្អក៏ចេញមក ។

ឆម្តាសត្វស្វាជាសត្វខឹល　　មាត់តែងរអិលគ្មានឈប់ឈរ
ទោះស្តីយ៉ាងណាតែងឧទ្ធរណ៍　　រីករំលឹកមិនបេះស្បៀម ៗ
រាជ្ញាខ្ញុំឯងផ្ទួសបរណៃ　　ផ្តាំទៅនឹងយាយដល់ព្រះរៀម
សូមឲ្យអញ្ជើញកុំជិនផៀម　　ឃើញស្អកហើយបៀមទុកធ្វើអ្វី ៗ
ពាក្យចាស់បុរាណតែងចងទុក　　ធ្វើសត្វកំប្រុកកុំខ្លាចព្រៃ
បើនឹងធ្វើស្រែទាន់ក្តៅដី　　បើនឹងចង់ស្រីទាន់ក្តៅចិត្ត ៗ
ឥឡូវមកដល់ដែនសេមា　　ចំណែកគង់តាលោកអាណិត
នឹងផ្តាំខ្ញុំឯងនៃក្រែងខុសក្រិត្យ　　បន់ឆៀងបន់ផិតមិនសមហេតុ ៗ
ប្រាប់ខ្ញុំយប់មិញឲ្យខ្ញុំថា　　យាយមកកាលណាកុំបណ្តែត
ជួយផ្សំកិច្ចការឲ្យសមហេតុ　　ស្ទុះក្អែតឈរមុខនាងក្សត្រី ៗ
ឯនាងឃើញហើយខឹងកន្ទួង　　ទឹកមុខទៅជាគាំងសំដី
ទឹកមុខចង់សើចមិនថាអ្វី　　ហួសចិត្តពេកក្រៃទើបស្តីថា ៗ
នៃឯងកុំមកបេះល្ហល្ហាច　　វោហាព្រោកប្រាជ្ញធ្វើឫកមហា
ពាក្យពេជអស់នេះបានពីណា　　អញគ្មានដែលថាមួយដងសោះ ៗ

នៅមានតទៅទៀត

សៀវភៅនេះមានជាវជុំ នឹងលក់រាយ នៅផ្ទះបិតរូបនឹង
លក់សៀវភៅ លេខ ២២៩ ផ្លូវវិវេរដង់ ទល់មុខផ្សារស្ទួន
ថ្មី ក្រុង ភ្នំពេញ

បើលោក-អ្នកត្រូវការប្រញាប់ ឲ្យទៅសួរ
ពីផ្ទះ ហេង-បៃ នៅផ្សារស៊ីញែកមាត់ទន្លេ ផ្ទះ
២១ ផ្លូវកេស៊ីស្សូវត្ត ព្រោះមានផ្ញើទុកនៅកន្លែងនោះ

ថ្លៃ ៦,០០

រោងពុម្ព ម៉ាន-វ៉ើ ភ្នំពេញ
លេខ ៨៣ ផ្លូវហ្សុីញី